**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 02-Aug-2011, 15:29
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

---

<u>ដាក់ដោយ៖</u>

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Ms. Elisabeth SIMONNEAU FORT

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គឹមសួន

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូ មណី

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Silke STUDZINSKY
Philippine SUTZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវាន

Jacques VERGES

## I ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់ជូនតុលាការ នូវបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យធ្វើការកោះហៅ ដើម្បីចូលមកបង្ហាញខ្លួននៅពេលសវនាការ[១]។ សារណានោះបានបញ្ជាក់ថា សាក្សីមួយចំនួនត្រូវបានដកចេញពីបញ្ជី ដោយសារសហព្រះរាជអាជ្ញា នឹងត្រូវដាក់បញ្ចូលជាភស្តុតាងនូវ "ចម្លើយរបស់សាក្សីនានា និងឯកសារពាក់ព័ន្ធផ្សេងៗ" ជំនួសឲ្យការចូលបង្ហាញខ្លួននៅក្នុងសវនាការ[២]។

២. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់ចម្លើយតប ដោយក្នុងចម្លើយតបនោះ មេធាវីការពារក្តីបានអះអាងថា អៀង សារី នឹង "ប្រើប្រាស់សិទ្ធិក្នុងការតទល់ជាមួយសាក្សីទាំងអស់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងរូបគាត់" ដោយ "ជំទាស់នឹងការប្រើប្រាស់ចម្លើយរបស់សាក្សីណាមួយ ដែលមិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម"[៣]។

៣. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី នួន ជា បានដាក់បញ្ជីឈ្មោះសាក្សី ដែលក្នុងនោះមេធាវីការពារក្តីបានកត់សម្គាល់នូវចេតនារបស់សហព្រះរាជអាជ្ញា ក្នុងការដាក់បញ្ចូលជាភស្តុតាងនូវចម្លើយរបស់សាក្សីនានា ហើយមេធាវីការពារក្តី "សូមរក្សាសិទ្ធិស្នើកោះហៅសាក្សីជាបុគ្គលណាមួយ និងគ្រប់សាក្សីទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីដែលផ្តល់ដោយ ក.ស.ព (ឬភាគីដទៃ) ដែលត្រូវបានអង្គជំនុំជម្រះទទួលយក"[៤]។

---

[១] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥ E9/4 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

[២] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១០។

[៣] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ E9/4/1 ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២។

[៤] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើង E9/4/4 ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៨។

៤. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់ចម្លើយតប ដែលក្នុងចម្លើយតបនោះមេធាវីការពារក្តីអះអាងថា "ក្នុងសវនាការ ខ្លួនមានសិទ្ធិសួរដេញដោលសាក្សីទាំងឡាយដែលបានផ្តល់ចម្លើយនៅដំណាក់កាលស៊ើបសួរ ប៉ុន្តែពុំទាន់បានជួបតទល់ជាមួយជនត្រូវចោទ"[៥]។

៥. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានមួយ ដែលក្នុងសេចក្តីសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាគាំទ្រដល់អំណាចរបស់តុលាការក្នុងការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដោយមិនចាំបាច់តម្រូវឱ្យសាក្សីបង្ហាញខ្លួនសម្រាប់ការតទល់នោះឡើយ[៦]។ សហព្រះរាជអាជ្ញាបានលើកឡើងនូវទឡ្ហីករណ៍ថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អនុញ្ញាតឱ្យដាក់ចម្លើយរបស់សាក្សី ដោយមិនមានការតទល់ជាមួយសាក្សីនោះឡើយ ដែលការអនុញ្ញាតនេះអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ ហើយដោយផ្អែកទៅលើខ្លឹមសារ ព្រមទាំងលក្ខណៈនៃការកត់ត្រាចម្លើយទាំងអស់នោះផងដែរ។ សហព្រះរាជអាជ្ញា បានលើកទឡ្ហីករណ៍នេះឡើង ដោយពឹងផ្អែកទៅលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងទៅលើការវិភាគពីការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន។

៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបនេះ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២។

## II សេចក្តីសង្ខេប លើទឡ្ហីករណ៍

៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគាំទ្រទាំងស្រុង ចំពោះជំហររបស់សហព្រះរាជអាជ្ញា ដែលបានបង្ហាញក្នុង សេចក្តីសន្និដ្ឋានរបស់ខ្លួនអនុលោមតាមវិធាន ៩២ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ដែលបានផ្ញើជូនអង្គជំនុំជម្រះសាលា

[៥] សេចក្តីបញ្ជាក់របស់អ្នកស្រី អៀង ធីរិទ្ធ អំពីចេតនាជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា E9/4/11 ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤។

[៦] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ E96 ("សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា")។

ដំបូង ដែលថាជនជាប់ចោទមិនមានសិទ្ធិដាច់ខាតណាមួយទេ ក្នុងការកោះហៅ និងសាកសួរសាក្សី ដែលចម្លើយរបស់ពួកគាត់ទាំងនោះត្រូវបានដាក់បញ្ចូលជាភស្តុតាង។

៨. ទាំងនីតិវិធីរបស់ អ.វ.ត.ក ក៏ដូចជានីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានផ្តល់នូវសិទ្ធិដាច់ខាតក្នុងការតទល់នោះទេ។ ផ្ទុយទៅវិញ សិទ្ធិក្នុងការតទល់ត្រូវបានកំណត់លក្ខខណ្ឌ ដោយផ្អែកទៅលើតម្លៃរបស់សំណើ សម្រាប់ការសម្រេចទៅលើការពិត ធៀបជាមួយនឹងចំណាយទៅលើប្រសិទ្ធភាពនៃការជំនុំជម្រះ។ ក្នុងករណីដែលបទប្បញ្ញត្តិទាំងនេះមានលក្ខណៈមិនច្បាស់លាស់ ឬផ្ទុយគ្នា អង្គជំនុំជម្រះគួរពិនិត្យមើលទៅលើច្បាប់ និងបទដ្ឋានអន្តរជាតិ ទាក់ទងដល់ការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ។ ច្បាប់ជាតិកម្ពុជា ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់ រួមបញ្ចូលទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិ ពុំបានផ្តល់នូវសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សីនោះឡើយ។ សំណើសុំឲ្យមានសិទ្ធិដាច់ខាតបែបនេះ នឹងប្រឆាំងទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយសំណើបែបនេះនឹងរារាំងដល់ការទទួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការគ្រប់គ្រងទៅលើដំណើរការនីតិវិធីដែលប្រកបដោយយុត្តិធម៌ និងមានប្រសិទ្ធភាព។

៩. ក្នុងពេលអនុវត្តគោលការណ៍អន្តរជាតិ ចំពោះដំណើរការនីតិវិធីបច្ចុប្បន្ននេះ អង្គជំនុំជម្រះគួរពិចារណាទៅលើនីតិវិធីពិសេស ទាក់ទងដល់ការចូលរួមរបស់ជនរងគ្រោះ នៅចំពោះមុខ អ.វ.ត.ក។

## III វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ព្រមទាំងច្បាប់កម្ពុជាមិនបានចែងពីសិទ្ធិដាច់ខាតក្នុងការតទល់ទេ

១០. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ស្របជាមួយការវិភាគរបស់សហព្រះរាជអាជ្ញា ទៅលើវិធាន ៨៧ និងវិធាន ៨៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ហើយយើងឯកភាពថា បទប្បញ្ញត្តិទាំងនេះមានភាពមិនច្បាស់លាស់ខ្លះៗ ទាក់ទិនដល់ប្រភេទនៃភស្តុតាងដែលត្រូវធ្វើការតទល់ដេញដោល[៧]។ បន្ថែមពីលើនេះ សិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សី មិនស្ថិតនៅក្នុងគម្រោងការនីតិវិធីរបស់ អ.វ.ត.ក ទេ។

[៧] សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ៣ ដល់៥។

១១. វិធាន ៨៧ ស្ដីពីវិធាននៃភ័ស្តុតាង បានចែងពីលក្ខណៈពិសេសនៃគោលការណ៍ សម្រាប់ការប្រព្រឹត្ត ចំពោះភ័ស្តុតាង នៅក្នុងប្រព័ន្ធច្បាប់ Civil Law ហើយថា "រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"[៨]។

១២. លើសពីនេះទៅទៀត បន្ទាប់ពីដីកាដំណោះស្រាយត្រូវបានប្រកាស ហើយដោយអនុលោមទៅតាម វិធាន ៦៩ រាល់ឯកសារ និងភ័ស្តុតាងទាំងអស់ដែលបានប្រមូលនៅក្នុងដំណាក់កាលស៊ើបអង្កេត ត្រូវធ្វើការបិទភ្ជិតដោយមានបោះត្រា ហើយបញ្ជូនទៅឲ្យអង្គជំនុំជម្រះសាលាដំបូង[៩]។ នៅក្នុងតុលាការប្រព័ន្ធ Civil Law ដូចជា អ.វ.ត.ក ជាដើម សំណុំរឿងបង្កើតជាមូលដ្ឋានអង្គហេតុ និងភ័ស្តុតាង ហើយដំណាក់កាលជំនុំជម្រះ ក្នុងដំណើរការនីតិវិធី ត្រូវបង្កើតឡើងដោយផ្អែកលើមូលដ្ឋាននេះ។ ផ្ទុយទៅនឹងទទ្ទឹករណ៍របស់ជនជាប់ចោទ ការចាប់ផ្ដើមដំណាក់កាលជំនុំជម្រះ មិនមែនជាការបញ្ជាក់ប្រាប់ថា នេះជាឱកាសសម្រាប់ការវាយតម្លៃឡើងវិញជារួម ទៅលើការទទួលយកសក្ខីកម្មរបស់សាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។

១៣. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមបកស្រាយបន្ថែមទៅលើការវិភាគនេះ តាមរយៈការកត់សម្គាល់ថា សិទ្ធិដែលក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ("ក្រម") បានផ្ដល់ឲ្យសម្រាប់ការតទល់ជាមួយសាក្សី ជាសិទ្ធិមិនដាច់ខាត មិនមែនជាសិទ្ធិដាច់ខាតនោះទេ។ សិទ្ធិនេះក៏អនុញ្ញាតឲ្យមានការទទួលយកនូវសក្ខីកម្មដោយមិនផ្ទាល់មាត់មួយចំនួន ដោយអាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ មាត្រា ២៩៧ នៃក្រមនេះបានចែងថា "សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ"[១០]។ បើទោះបីជាតុលាការមិនយល់ស្របជាមួយនឹងការវិភាគរបស់សហព្រះរាជអាជ្ញា ដោយថាអត្ថន័យនៃពាក្យ "ដាក់បន្ទុក"

[៨] វិធាន ៨៧(១)។

[៩] វិធាន ៦៩(១)។

[១០] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បកប្រែភាសាខ្មែរ-អង់គ្លេស បោះពុម្ពលើទីមួយ ខែកញ្ញា ឆ្នាំ ២០០៨ ("នីតិវិធីព្រហ្មទណ្ឌ")

មានលក្ខណៈមិនច្បាស់លាស់[១១] ក៏ដោយ ក៏មាត្រា ៣១៨ បានកម្រិតកំណត់ទៅលើវិសាលភាពនៃសិទ្ធិនេះដែរ។

១៤. មាត្រា ៣១៨ នៃក្រមបានផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវឆន្ទានុសិទ្ធិយ៉ាងច្បាស់ ក្នុងការបដិសេធសំណើសុំណាមួយ ដែលបានដាក់នៅចំពោះមុខតុលាការ។ "ប្រធានសវនាការអាចបដិសេធចេញពីការពិភាក្សាដេញដោល នូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសម្តែងឲ្យឃើញការពិត"។ ឆន្ទានុសិទ្ធិក្នុងការ "បដិសេធនូវអ្វីៗទាំងអស់" ពិតជារួមបញ្ចូលទាំងអំណាចក្នុងការបដិសេធការតទល់ដោយផ្ទាល់មាត់ ព្រមទាំងការពិចារណាទៅលើខ្លឹមសារនៃភ័ស្តុតាង ក្នុងពេលធ្វើការសម្រេចទៅលើបទដ្ឋានសមស្របសម្រាប់ការទទួលយក[ភ័ស្តុតាង]។ ឆន្ទានុសិទ្ធិបែបនេះត្រូវតែប្រើប្រាស់ដោយប្រុងប្រយ័ត្ន ក៏ប៉ុន្តែប្រាកដណាស់ថាឆន្ទានុសិទ្ធិបែបនេះ គឺពិតជាមាន។ ការអះអាងរបស់មេធាវីការពារក្តីដែលថា ការតទល់គឺជាការចាំបាច់ ឬក៏ការដែលពួកគាត់បានលើកឡើងថា ឆន្ទានុសិទ្ធិបែបនេះអាចមានតែក្នុងករណីដែលជនជាប់ចោទប្រើប្រាស់សិទ្ធិក្នុងការបោះបង់ចោលការតទល់នោះ គឺជាការមើលរំលងទៅលើបទប្បញ្ញត្តិដែលមានចែងយ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

១៥. តាមទស្សនៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឆន្ទានុសិទ្ធិរបស់តុលាការដែលមានចែងក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានកំណត់នូវលក្ខខណ្ឌសម្រាប់សិទ្ធិក្នុងការតទល់ ដែលមានចែងក្នុងមាត្រា ២៩៧ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិក្នុងការទទួលយកភ័ស្តុតាងជាលាយលក្ខណ៍អក្សរដោយមិនចាំបាច់មានការតទល់ ប្រសិនបើការធ្វើដូច្នេះជាការជួយពន្លឿនដល់ការស្វែងរកការពិត ព្រមទាំងជួយធានាដល់ការជំនុំជម្រះមួយប្រកបដោយប្រសិទ្ធភាព ហើយគ្មានបុរេវិនិច្ឆ័យចំពោះសិទ្ធិរបស់ភាគីណាមួយនោះ។ ភាពមិនប្រាកដប្រជាគឺនៅត្រង់ថាតើ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រើប្រាស់បទដ្ឋានបែបណា ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងសំណុំរឿងនេះ មិនមែនស្ថិតត្រង់ថាតើអង្គជំនុំជម្រះមានអំណាចបែបនេះ ឬអត់នោះទេ។ ហេតុដូច្នេះទាំងច្បាប់កម្ពុជា ក៏ដូចជាវិធានផ្ទៃ

[១១] សូមមើលសេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

ក្នុងរបស់ អ.វ.ត.ក គឺមិនបានឆ្លើយតបទៅនឹងសំណួរទាក់ទងទៅនឹងការបកស្រាយទៅលើខ្លឹមសារនៃច្បាប់ ឬវិធានរបស់ខ្លួននោះទេ។

## IV **ភាពមិនប្រាកដប្រជាចំពោះខ្លឹមសារ ឬបទដ្ឋាននៃសិទ្ធិមិនដាក់ខាតខ្លួនការតទល់ គួរត្រូវបានដោះស្រាយ ដោយយោងទៅលើការអនុវត្តកម្រិតអន្តរជាតិ**

១៦. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក គាំទ្រដល់ការអនុវត្តបទដ្ឋានអន្តរជាតិសម្រាប់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលវិធាន និងនីតិវិធីបែបនេះមិនមានភាពពេញលេញ[១២]។ សម្រាប់សំអាងហេតុ ដូចបានរៀបរាប់ពីខាងលើ ហើយដោយស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាគោលការណ៍ណែនាំដែលយកចេញពីបទដ្ឋានអន្តរជាតិគឺសមស្រប ព្រោះដោយសារមានភាពមិនប្រាកដប្រជាទាក់ទងនឹង ១) ការបកស្រាយ ឬការអនុវត្តចំពោះវិធាននីតិវិធីដែលពាក់ព័ន្ធ ក្នុងច្បាប់កម្ពុជា ២) ភាពសមស្របគ្នាជាមួយបទដ្ឋានអន្តរជាតិ[១៣]។

១៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

[១២] សូមមើលវិធាន ២ (“នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើប អង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និង មាត្រា ២០ថ្មី, ២៣ថ្មី, ៣៣ថ្មី ឬមាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និង ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន ។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន”)

[១៣] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា ១២ (“នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហា ពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិគេអាចស្វែង រកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ") សូមមើលផងដែរច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ បូករួមជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា ៣៣។

សូមទទួលយកនូវទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា[១៤] ដែលថា នៅមានចន្លោះប្រហោងមួយចំនួននៅក្នុងនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ទាក់ទងទៅនឹងការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ។ ការយោងទៅលើច្បាប់កម្ពុជា មិនអាចដោះស្រាយភាពប្រទាំងប្រទើសគ្នានេះបានឡើយ។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្តល់នូវសិទ្ធិដាច់ខាតក្នុងការតទល់ ពេលនោះអង្គជំនុំជម្រះនឹងត្រូវដោះស្រាយទៅលើការខ្វែងគ្នាដោយផ្ទាល់រវាងការបកស្រាយមួយនេះ ជាមួយនឹងអត្ថន័យយ៉ាងសាមញ្ញនៅក្នុងមាត្រា ៣១៨។ ជាថ្មីម្តងទៀត ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ច្បាប់អន្តរជាតិគួរជួយដល់សេចក្តីសម្រេចរបស់តុលាការ ក្នុងករណីដែលតម្រូវការនីតិវិធីមិនស៊ីសង្វាក់គ្នា[១៥]។

១៨. ក្នុងពេលកន្លងមក តុលាការ អ.វ.ត.ក បានពឹងផ្អែកទៅលើបទដ្ឋានគតិយុត្តិអន្តរជាតិ ក្នុងការសម្រេចទៅលើការទទួលយកភ័ស្តុតាងប្រយោល[១៦]។ ជាឧទាហរណ៍ អៀង សារីបានដកស្រង់សេចក្តីសម្រេចក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ (ហៅ "ឌុច")[១៧] ដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេច ថាតើចម្លើយរបស់សាក្សីពីររូបដែលបានសម្ភាសន៍ដោយអ្នកតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលសាក្សីទាំងពីររូបនេះបានទទួលមរណភាពទៅហើយនោះ គួរត្រូវបានដក

---

[១៤] សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[១៥] ដូចជើងទំព័រខាងលើ។

[១៦] អង្គជំនុំជម្រះបានពិនិត្យមើលលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម (CAT) ក្នុងការសម្រេចថាតើចម្លើយមួយចំនួនដែលបានធ្វើឡើងក្នុងពេលដែលសាក្សីត្រូវបានគេធ្វើទារុណកម្ម អាចត្រូវដកចេញពីភ័ស្តុតាង។ សូមមើលសាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ D130/9/21 ២៧ ដល់២៩ (ដកស្រង់នូវដីកាសម្រេចលើសំណើរបស់ភាគីនានាដើម្បីដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(២) ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ E176 កថាខណ្ឌ ៨) សូមមើលផងដែរសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ D404/2/4 កថាខណ្ឌ ៥៨ ដល់៦០។

[១៧] សូមមើលចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ខែ កុម្ភៈ ឆ្នាំ ២០១១ E9/4/1 (ដកស្រង់សេចក្តីសម្រេចលើការទទួលយកសម្ភារៈនៅក្នុងសំណុំរឿង ជាភ័ស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/3 កថាខណ្ឌ ១៦)

ចេញតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងឬទេ។ មេធាវីការពារជនជាប់ចោទ បានបកស្រាយខុស ចំពោះសេចក្តីសម្រេចនេះ នៅពេលដែលខ្លួនបញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូង បដិសេធការ ទទួលស្គាល់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីពីររូប ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារ កម្ពុជា ពីព្រោះសាក្សីបានស្លាប់មុនពេលសវនាការ ហើយ ឌុច មិនមានលទ្ធភាពតទល់ភាពត្រឹមត្រូវ នៃចម្លើយរបស់សាក្សីទាំងនោះ"[១៨]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះក្នុងពេលធ្វើការសម្រេច បានពិនិត្យ មើលទៅលើកត្តាជាច្រើន ដោយមិនផ្អែកតែទៅលើកត្តាដែលជនជាប់ចោទមិនអាចសួរដេញដោល សាក្សីនោះទេ ហើយអង្គជំនុំជម្រះបានពឹងផ្អែកយ៉ាងច្រើនទៅលើសេចក្តីសម្រេចរបស់អង្គតុលាការ អន្តរជាតិដទៃទៀត ពិសេសគឺតុលាការ ICTY[១៩]។ ជាអវសាន្ត អង្គជំនុំជម្រះសាលាដំបូងបាន បដិសេធភ័ស្តុតាងនេះដោយសារមូលដ្ឋានជាច្រើន ដែលក្នុងនោះរួមមានអង្គហេតុដែលថា ចម្លើយ សាក្សីនីមួយៗ បាននិយាយយោងទៅដល់អំពើ និងការប្រព្រឹត្តឧក្រិដ្ឋរបស់ជនជាប់ចោទ[២០]។

## V សិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សី មិនមាននៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ តុលាការព្រហ្មទណ្ឌក្នុងកាត់ណាមួយឡើយ

១៩. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ស្រប ជាមួយសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា បទដ្ឋានអន្តរជាតិមិនបានផ្តល់ដល់ជនជាប់ ចោទនូវសិទ្ធិដាច់ខាត ក្នុងការកោះហៅ និងសាកសួរសាក្សីនៅក្នុងពេលសវនាការនោះឡើយ[២១] ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមផ្តល់នូវទឡ្ហីករណ៍បន្ថែមដើម្បីគាំទ្រចំពោះសេចក្តីសន្និដ្ឋាននេះដូចតទៅ៖

### ក. តុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍*

---

[១៨] ដូចជើងទំព័រខាងលើ ជើងទំព័រ ១២។

[១៩] សេចក្តីសម្រេចលើការទទួលយកសម្ភារៈនៅក្នុងសំណុំរឿង ជាភ័ស្តុតាង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ E43/3 កថាខណ្ឌ ១៥ និង១៦។

[២០] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៦។

[២១] សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ២។

២០. ដើមបណ្ដឹងរដ្ឋប្បវេណីយល់ស្របជាមួយនឹងការពិភាក្សារបស់សហព្រះរាជអាជ្ញា ស្ដីពីសិទ្ធិក្នុងការតទល់ជាមួយសាក្សីដោយសិទ្ធិមិនដាច់ខាត ដែលប្រើប្រាស់នៅតុលាការ ICTY ដោយបានផ្ដល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ហើយបានផ្ដល់នូវការរៀបរាប់ពីកត្តាមួយចំនួនដែលត្រូវពិចារណា នៅពេលសម្រេចពីការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ជំនួសឲ្យការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់[២២]។ ដើមបណ្ដឹងរដ្ឋប្បវេណី សូមបន្ថែមថា វិធាន ៩២ស្ទួន នៃវិធានស្ដីពីភ័ស្ដុតាង និងនីតិវិធី របស់តុលាការ ICTR មានលក្ខណៈសឹងតែដូចគ្នាបេះបិទទៅនឹងបទប្បញ្ញត្តិរបស់តុលាការ ICTY ដែលបានលើកយកមកពិភាក្សានៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា[២៣]។ វិធាននេះត្រូវបានអនុវត្តចំពោះរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Ndindabahizi*[២៤], *រដ្ឋអាជ្ញា តទល់នឹង Nzabonimana*[២៥], ព្រមទាំងរឿងក្ដីដទៃ

---

[២២] សេចក្ដីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ១២ ដល់ ២១។

[២៣] វិធាន ៩២ស្ទួន វិធានស្ដីពីភ័ស្ដុតាង និងនីតិវិធី របស់តុលាការ ICTR ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៩ (“តឹកតាងនៃអង្គហេតុ ក្រៅពីភស្ដុតាងដោយផ្ទាល់មាត់”) (ក) អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកទាំងស្រុង ឬមួយផ្នែក នូវភ័ស្ដុតាងរបស់សាក្សីណាម្នាក់ ក្នុងទម្រង់ជាកំណត់ហេតុស្ដាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ដែលត្រូវប្រើធ្វើជាតឹកតាងលើបញ្ហាអ្វីមួយក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (i) កត្តានានាដែលស្របទៅនឹងការទទួលយកភស្ដុតាងក្នុងទម្រង់ជាកំណត់ហេតុស្ដាប់ចម្លើយ រួមមាន ក៏ប៉ុន្ដែមិនកំណត់ត្រឹមតែកាលៈទេសៈនៃភ័ស្ដុតាងនោះទេ៖ (ក) មានចរិតលក្ខណៈត្រួតគ្នា ដែលនៅក្នុងនោះសាក្សីដទៃទៀតនឹងផ្ដល់ ឬបានផ្ដល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា។ (ខ) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលមានការពាក់ព័ន្ធ។ (គ) មានការវិភាគមួយជាទូទៅ ឬជាស្ថិតិស្ដីពីសមាសភាគជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានា ដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (ឃ) មានការបារម្ភពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។ (ង) មានការទាក់ទងនឹងបញ្ហានានាស្ដីពីអាកប្បកិរិយារបស់ជនជាប់ចោទ ឬមួយក៏ (ច) មានការទាក់ទងនឹងកត្តានានាដែលគេត្រូវយកមកពិចារណានៅក្នុងការកំណត់ទោស។ (ii) កត្តានានាដែលប្រឆាំងទៅនឹងការទទួលយកភស្ដុតាងក្នុងទម្រង់ជាកំណត់ហេតុស្ដាប់ចម្លើយ រួមមានថាតើ៖ (ក) មានផលប្រយោជន៍សាធារណៈដ៏លើសលប់ នៅក្នុងភស្ដុតាងដែលត្រូវបង្ហាញដោយផ្ទាល់មាត់។ (ខ) ភាគីជំទាស់អាចបង្ហាញបានថា ចរិតលក្ខណៈ និងប្រភពរបស់វា មិនអាចធ្វើឲ្យគេទុកចិត្តបាន ឬបង្ហាញថា អានុភាពបុរេវិនិច្ឆ័យមានតម្លៃធ្ងន់ជាង តម្លៃជាភស្តុតាងរបស់វា ឬមួយក៏ (គ) មានកត្តាផ្សេងៗទៀត ដែលធ្វើឲ្យវាមានលក្ខណៈសមស្របចំពោះសាក្សីរូបនោះ ចូលមកបង្ហាញខ្លួនសម្រាប់ការសាកសួរសាក្សីបដិបក្ខ”។

[២៤] Emmanuel Ndindabahizi (ម្ចាស់បណ្ដឹងឧទ្ធរណ៍) តទល់នឹង រដ្ឋអាជ្ញា (ម្ចាស់ចម្លើយតប) ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧ រឿងក្ដី ICTR-01-71-A, កថាខណ្ឌ ៩៦ ដល់៩៨ (សម្រេចថា អង្គជំនុំជម្រះសាលាដំបូង បានបដិសេធដោយត្រឹមត្រូវ ទៅលើ

ទៀត ហើយការបកស្រាយទៅលើវិធាននេះ គឺមិនមានភាពខុសគ្នាជាចម្បងនោះឡើយ ធៀបជាមួយនឹងវិធានរបស់តុលាការ ICTY។

## ខ. តុលាការព្រហ្មទណ្ឌកូនកាត់ *មិនអចិន្ត្រៃយ៍*

២១. ដើមបណ្តឹងរដ្ឋប្បវេណីក៏ឯកភាពផងដែរជាមួយនឹងសហព្រះរាជអាជ្ញាដែលលើកឡើងថា តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន បានអនុម័តដូចគ្នានូវសិទ្ធិក្នុងការតទល់ដោយសិទ្ធិមិនដាច់ខាត[២៦]។ ដើមបណ្តឹងរដ្ឋប្បវេណីសូមបន្ថែមទៀតថា វិធានស្តីពីនីតិវិធី និងភ័ស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ មានរួមបញ្ចូលនូវបទប្បញ្ញត្តិដែលសឹងតែដូចគ្នាបេះបិទជាមួយនឹងវិធាននៅតុលាការ ICTY និង ICTR ដែលចែងពីចំណុចដូចគ្នានេះ[២៧]។

---

សារណារបស់មេធាវីការពារក្តី ដែលស្នើដាក់សក្ខីកម្មជាលាយលក្ខណ៍អក្សរ ដោយមិនមានការតទល់ ក្នុងករណីដែលខ្លឹមសារមួយចំនួន "និយាយដល់បញ្ហាអំពើនិង ការប្រព្រឹត្ត" ហើយផ្នែកដែលនៅសល់នៅក្នុងសក្ខីកម្ម គឺមាន "លក្ខណៈពាក់ព័ន្ធ" ជាមួយផ្នែកនៃឯកសារដែលត្រូវបានបដិសេធចោលនោះ)។

[២៥] រដ្ឋអាជ្ញា តទល់និង Nzabonimana, Case No. ZCTR-98-44D-T សេចក្តីសម្រេចលើសំណើសុំដាក់ឯកសារប្រតិចារឹករបស់រឿងក្តី *Bizimungu* និងអ្នកដទៃទៀត (វិធាន ៩២ស្ទួន(ឃ) និង ៨៩(គ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង) ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ (សម្រេចថា សក្ខីកម្មជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ដោយពុំចាំបាច់មានការតទល់ ក្នុងករណីដែលភ័ស្តុតាងនោះមិនបានរៀបរាប់ ឬពណ៌នាចំពោះជនជាប់ចោទដោយផ្ទាល់)។

[២៦] សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤ បានដកស្រង់អនុវិធាន ៩២ស្ទួន(ក) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលចែងថា ("ជាបន្ថែមពីលើវិធាន៩២ស្ទួនបួន អង្គជំនុំជម្រះអាចទទួលយកជាភ័ស្តុតាងមួយផ្នែក ឬទាំងមូល ជាជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់បាន នៃព័ត៌មានដែលរួមទាំងចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកទាំងឡាយណាដែលមិនមែនជាការបង្ហាញតឹកតាងពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ"។

[២៧] វិធាន ១៥៥ នៃវិធានស្តីពីភ័ស្តុតាង និងនីតិវិធី របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយបានកែប្រែនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់។ (ក) អនុលោមទៅតាមវិធាន ១៥៨ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកនូវភ័ស្តុតាងរបស់សាក្សីណាម្នាក់ ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬជាប្រតិចារឹក ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដែលផ្តល់ឱ្យដោយសាក្សី ក្នុងដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវប្រើធ្វើជាតឹកតាងលើបញ្ហាអ្វីមួយក្រៅពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (i) កត្តានានាដែលស្របទៅនឹងការទទួលយកភ័ស្តុតាងក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ រួមមាន ក៏ប៉ុន្តែមិនកំណត់ត្រឹមតែកាលៈទេសៈនៃភ័ស្តុតាង

## គ. តុលាការព្រហ្មទណ្ឌអន្តរជាតិ

២២. តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់ដល់ភាគីនានា នូវសិទ្ធិក្នុងការតទល់ជាមួយសាក្សី ដោយមានសិទ្ធិមិនដាច់ខាត មិនមែនផ្តល់ឲ្យនូវសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សីនោះឡើយ។ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាបានដកស្រង់សេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានអនុវត្តនូវមាត្រា ៦៩(២) នៃលក្ខន្តិកទីក្រុងរ៉ូម ក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលបានកត់ត្រាទុកជាមុន ដោយមិនចាំបាច់មានការតទល់ជាមួយសាក្សី[២៨]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា បទប្បញ្ញត្តិបន្ថែមផ្សេងទៀត នៅក្នុងលក្ខន្តិកទីក្រុងរ៉ូម ក៏មានចែងពីការទទួលយកតាមឆន្ទានុសិទ្ធិ ដោយមិនចាំបាច់មានការតទល់នោះឡើយ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិ បានបកស្រាយទៅលើមាត្រាទាំងអស់នេះរួមគ្នា ដើម្បីសម្រេចថាសិទ្ធិរបស់ភាគីក្នុងការតទល់ជាមួយសាក្សី គឺជាសិទ្ធិមិនដាច់ខាត។ នៅក្នុងសេចក្តីសម្រេចក្រោយមួយទៀត បន្ទាប់ពីសេចក្តីសម្រេចដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Lubanga* បានពិនិត្យមើលទៅលើបទប្បញ្ញត្តិ

---

នោះទេ៖ (ក) មានចរិតលក្ខណៈត្រួតគ្នា ដែលនៅក្នុងនោះសាក្សីដទៃទៀតនឹងផ្តល់ ឬបានផ្តល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា។ (ខ) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលមានការពាក់ព័ន្ធ។ (គ) មានការវិភាគមួយជាទូទៅ ឬជាស្ថិតិស្តីពីសមាសភាគជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានា ដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ (ឃ) មានការបារម្ភពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។ (ង) មានការទាក់ទងនឹងបញ្ហានានាស្តីពីអាកប្បកិរិយារបស់ជនជាប់ចោទ ឬមួយក៏ (ច) មានការទាក់ទងនឹងកត្តានានាដែលគេត្រូវយកមកពិចារណានៅក្នុងការកំណត់ទោស។ (ii) កត្តានានាដែលប្រឆាំងទៅនឹងការទទួលយកភ័ស្តុតាងក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ រួមមានថាតើ៖ (ក) មានផលប្រយោជន៍សាធារណៈដ៏លើសលប់ នៅក្នុងភ័ស្តុតាងដែលត្រូវបង្ហាញដោយផ្ទាល់មាត់។ (ខ) ភាគីជំទាស់អាចបង្ហាញបានថា ចរិតលក្ខណៈ និងប្រភពរបស់វា មិនអាចធ្វើឲ្យគេទុកចិត្តបាន ឬបង្ហាញថា អានុភាពបុរេវិនិច្ឆ័យមានតម្លៃធ្ងន់ជាង តម្លៃជាភស្តុតាងរបស់វា ឬមួយក៏ (គ) មានកត្តាផ្សេងៗទៀត ដែលធ្វើឲ្យវាមានលក្ខណៈសមស្របចំពោះសាក្សីរូបនោះចូលមកបង្ហាញខ្លួនសម្រាប់ការសាកសួរសាក្សីបដិបក្ខ"។

[២៨] សេចក្តីសន្និដ្ឋានរបស់ សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨ បានដកស្រង់រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo, ICC-01/04-01/06, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា អំពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានកត់ត្រាទុកជាមុន របស់សាក្សីចំនួនពីររូប ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ (ដោយដកស្រង់នូវមាត្រា ៦៩(២) នៃលក្ខន្តិកទីក្រុងរ៉ូម នៃ តុលាការព្រហ្មទណ្ឌអន្តរជាតិ)។

ទាំងអស់នៅក្នុងលក្ខន្តិកទីក្រុងរ៉ូម ព្រមទាំងវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC ហើយ បានសម្រេចថា "ទោះបីជាមានការយោងយ៉ាងច្បាស់ទៅលើភស្តុតាងដោយផ្ទាល់មាត់របស់សាក្សី នៅក្នុងសវនាការក៏ដោយ ក៏មានការទទួលស្គាល់យ៉ាងច្បាស់លាស់ថា មានមធ្យោបាយដទៃទៀតជាច្រើនក្នុងការបង្ហាញភស្តុតាងដែលមានលក្ខណៈសមស្រប"[២៩]។

២៣. នៅក្នុងរឿងក្ដី *Lubanga* អង្គជំនុំជម្រះសាលាដំបូងបានកំណត់នូវបទប្បញ្ញត្តិចំនួនប្រាំនៅក្នុងលក្ខន្តិកទីក្រុងរ៉ូម ដែលបានផ្ដល់ឆន្ទានុសិទ្ធិដល់ខ្លួន ក្នុងការទទួលយកភស្តុតាងដោយមិនតម្រូវឲ្យសាក្សីបង្ហាញខ្លួនសម្រាប់ការតទល់នោះឡើយ[៣០]។ មាត្រា ៦៩(៣) បានចែងថា តុលាការមាន "សមត្ថកិច្ចស្នើសុំឲ្យដាក់ភស្តុតាងទាំងអស់ដែលខ្លួនពិចារណាថា មានសារៈសំខាន់សម្រាប់ការសម្រេចលើការពិត"[៣១]។ មាត្រា ៦៩(៤) ចែងថា "តុលាការអាចសម្រេចទៅលើភាពពាក់ព័ន្ធ ឬការទទួលយកនូវភស្តុតាង ដោយពិចារណាពីតម្លៃភរនីយភាពរបស់ភស្តុតាង ព្រមទាំងពិចារណាលើបុរេវិនិច្ឆ័យ ដែលភស្តុតាងបែបនេះ អាចធ្វើឲ្យប៉ះពាល់ដល់ការជំនុំជម្រះប្រកបដោយយុត្តិធម៌ ឬដល់ការវាយតម្លៃប្រកបដោយយុត្តិធម៌ ចំពោះសក្ខីកម្មរបស់សាក្សី ដោយយោងទៅតាមវិធានស្ដីពីនីតិវិធី និងភស្តុតាង"[៣២]។ មាត្រា ៦៤(៩) ចែងថា តុលាការអាច "សម្រេចទៅលើការទទួលយក ឬភាពពាក់ព័ន្ធរបស់ភស្តុតាងនានា"[៣៣]។ មាត្រា ៦៩(២) អនុញ្ញាតឲ្យតុលាការទទួលយក "ឯកសារ ឬប្រតិចារឹកលាយលក្ខណ៍អក្សរ ដោយស្ថិតក្រោមលក្ខន្តិកមួយនេះ ព្រមទាំងអនុលោមទៅតាមវិធានស្ដីពីនីតិវិធី និងភស្តុតាង"[៣៤]។ ជាចុងក្រោយ មាត្រា ៦៨(២) ដោយអានរួមជាមួយនិងមាត្រា ៦៨(១) អនុញ្ញាតឲ្យតុលាការទទួលយកភស្តុតាង "តាមមធ្យោបាយអេឡិចត្រូនិក ឬមធ្យោបាយដទៃទៀត" ក្នុងករណី

[២៩] រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo, ICC-01/04-01/06 សេចក្ដីសម្រេចលើការទទួលយកឯកសារចំនួនបួន ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ("សេចក្ដីសម្រេច Lubanga") កថាខណ្ឌ ២២។

[៣០] ដូចជើងទំព័រខាងលើ។

[៣១] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២០។

[៣២] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៣។

[៣៣] ដូចជើងទំព័រខាងលើ។

[៣៤] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២២។

ចាំបាច់ដើម្បី "ការពារសុវត្ថិភាព សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងសេចក្តីថ្លៃថ្នូរ និងភាពឯកជនរបស់ជនរងគ្រោះ ព្រមទាំងសាក្សី"[៣៥]។

២៤. តុលាការបានសំយោគរួមនូវសមត្ថកិច្ចទាំងអស់នេះ ទៅក្នុងលក្ខណៈវិនិច្ឆ័យដែលមានបីផ្នែក ដើម្បីធ្វើការសម្រេចពីភាពអាចទទួលយកបានរបស់ភស្តុតាង ដែលស្ថិតក្នុងទម្រង់ផ្សេងខុសពីទម្រង់ជាសក្ខីកម្មដោយផ្ទាល់៖ ១) ភស្តុតាងត្រូវតែមានភាពពាក់ព័ន្ធ ២) ភស្តុតាងត្រូវតែមានតម្លៃភស្តុតាងនីយភាព និង ៣) តម្លៃភស្តុតាងនីយភាពនៃភស្តុតាងត្រូវតែបានធ្វើការថ្លឹងថ្លែងធៀបជាមួយផលប៉ះពាល់បុរេវិនិច្ឆ័យរបស់ភស្តុតាងនោះ[៣៦]។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានកម្រិតកំណត់ការវិភាគតែចំពោះ "បញ្ជីនៃលក្ខណៈវិនិច្ឆ័យ ដែលមានចំនួនកំណត់"[៣៧] នោះឡើយ។ ផ្ទុយទៅវិញ ការវាយតម្លៃគឺជាការសម្រេចចំពោះអង្គហេតុជាក់លាក់មួយ ដែលនឹងអាស្រ័យទៅលើ "បញ្ហានៅក្នុងរឿងក្តី និងបរិបទដែលសម្ភារៈនោះត្រូវដាក់បញ្ចូលទៅក្នុងគ្រោងការណ៍រួមនៃភស្តុតាង ព្រមទាំងការត្រួតពិនិត្យលម្អិតទៅលើកាលៈទេសៈនៃភស្តុតាងដែលរងការជំទាស់"[៣៨]។ តុលាការបានអនុវត្តលក្ខណៈវិនិច្ឆ័យនេះក្នុងដីកាបន្ទាប់ ស្តីពីការទទួលយកភស្តុតាង[៣៩]។

២៥. ទោះបីជាករណីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងនឹងបញ្ហាមួយនេះ មានចំនួនតិចតួចក៏ដោយ ក៏ករណីយុត្តិសាស្ត្រកំណត់ថា តុលាការអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដោយមិនចាំបាច់តទល់ជាមួយសាក្សីនោះទេ។ អង្គហេតុដែលជាបញ្ហា នៅក្នុងសេចក្តីសម្រេច Lubanga គឺពាក់ព័ន្ធជាមួយសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលមិនត្រូវបានកោះហៅឱ្យមកធ្វើសក្ខីកម្ម ហើយតុលាការបានសម្រេចថា ការដែលសាក្សីមិនអាចតទល់បាន "គឺជាការពិចារណាដ៏សំខាន់មួយ" ក៏ប៉ុន្តែវា "ខ្លួនឯងផ្ទាល់មិនមែនជាកត្តា

---

[៣៥] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៣។

[៣៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៧ ដល់៣១។

[៣៧] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៩។

[៣៨] សេចក្តីសម្រេច Lubanga កថាខណ្ឌ ២៩។

[៣៩] រដ្ឋអាជ្ញា តទល់និង Thomas Lubanga Dyilo, ICC-01/04-01/06,សេចក្តីសម្រេចស្តីពី "Quatrième requête de la Défense aux fins de dépôt de documents" ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៥ និងបន្ទាប់។

សម្រេច លើការទទួលយកភ័ស្តុតាងនោះឡើយ"[៤០]។ សេចក្តីសម្រេចនេះបានដកស្រង់យ៉ាងល្អនូវករណីយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលផ្អែកលើករណីយុត្តិសាស្ត្រនេះ "ការមិនមានឱកាសក្នុងការសួរដេញដោល ជាមួយបុគ្គលដែលបានផ្តល់ចម្លើយ គឺមានភាពពាក់ព័ន្ធ" ប៉ុន្តែវាមិនមែនជាកត្តាសម្រេចនោះឡើយ[៤១]។

២៦. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកភ័ស្តុតាងដោយមិនផ្ទាល់មាត់ នៅក្នុងរឿងក្តី *Lubanga* គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយរឿងក្តីនៅតុលាការ ICTY និង ICTR។ ចំណុចគន្លឹះពីរដំបូងនៅក្នុងលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺតម្លៃពាក់ព័ន្ធ និងតម្លៃភស្តុតាងនោះ ត្រូវបានគេដាក់បញ្ចូលទៅក្នុងវិធាន ៨៩(គ) របស់តុលាការ ICTY/ICTR[៤២]។ ចំណុចគន្លឹះទីបីរបស់លក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺការថ្លឹងថ្លែងតម្លៃភស្តុតាងនៃភ័ស្តុតាង ធៀបជាមួយផលប៉ះពាល់បុរេវិនិច្ឆ័យនោះ បានឆ្លើយតបទៅនឹងការព្រួយបារម្ភដូចគ្នាចំពោះភាពយុត្តិធម៌ ហើយដែលត្រូវបានដោះស្រាយតាមរយៈតម្រូវការយ៉ាងច្បាស់លាស់របស់តុលាការ ICTY/ICTR ដែលថាភស្តុតាងត្រូវបង្ហាញ "តឹកតាងនៃបញ្ហា មិនមែនតឹកតាងនៃអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទនោះឡើយ"[៤៣]។

២៧. សម្រាប់គោលដៅនៃបញ្ហាមួយនេះ វាមានភាពគ្រប់គ្រាន់ដើម្បីធ្វើការសន្និដ្ឋានថា បើទោះបីជាលក្ខន្តិកទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងពីអាទិភាពសម្រាប់សក្ខីកម្មដោយផ្ទាល់មាត់ក៏ដោយ ក៏បទដ្ឋានដែលអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនបានផ្តល់ដល់ភាគីនានានូវសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សីឡើយ។ តាមពិតទៅលក្ខណៈវិនិច្ឆ័យនៃភាពពាក់ព័ន្ធដែលកំណត់ឡើងដោយករណីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺប្រហាក់ប្រហែលគ្នាទាំងទម្រង់

---

[៤០] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៦។

[៤១] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨ ដកស្រង់ រដ្ឋអាជ្ញា តទល់នឹង Aleksovski, IT-95-14/1 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនិងការទទួលយកភ័ស្តុតាង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ (អាគតដ្ឋានក្នុងសាលដីកានេះ ត្រូវបានដកចេញ)

[៤២] វិធាន ៨៩(គ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង របស់តុលាការ ICTR ដែលត្រូវបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៩ ("អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងដែលពាក់ព័ន្ធទាំងឡាយណា ដែលអាចមានតម្លៃភស្តុតាងផងដែរ")។

[៤៣] វិធាន ៩២ស្ទួន(ក) វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY។

និងខ្លឹមសារ ជាមួយនឹងលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយលក្ខន្តិក ដែលបានប្រើប្រាស់នៅក្នុងតុលាការ ICTY និង ICTR ហើយវាបានផ្តល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចការទទួលយកភ័ស្តុតាងជាលាយលក្ខណ៍អក្សរ។

## VI **សិទ្ធិមិនដាច់ខាតក្នុងការតតាំងជាមួយសាក្សី ធ្វើឲ្យប្រសើរឡើងនូវតម្រូវការប្រសិទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង**

២៨. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមទទួលស្គាល់ថា សិទ្ធិទទួលបានយុត្តិធម៌ក្នុងនីតិវិធីគឺជាសិទ្ធិជាសារវន្តនៅចំពោះមុខតុលាការ អ.វ.ត.ក។ ក៏ប៉ុន្តែសំណើរបស់ជនជាប់ចោទសុំឲ្យមានសិទ្ធិដាច់ខាតក្នុងការសួរដេញដោលរាល់សាក្សីណា ដែលត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺផ្ទុយទៅនឹងកាតព្វកិច្ចជាសារវន្តរបស់តុលាការ អ.វ.ត.ក ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន ក្នុងពេលវេលាដ៏សមស្របមួយ[៤៤]។

២៩. អ.វ.ត.ក បានអនុវត្តនូវកត្តាតម្រូវសម្រាប់ប្រសិទ្ធភាពរបស់ខ្លួន ក្នុងពេលសម្រេចលើចំណោទបញ្ហាស្តីពីនីតិវិធីតុលាការក្នុងពេលកន្លងមកនោះ។ ជាឧទាហរណ៍ ក្នុងសំណុំរឿងនេះ អង្គបុរេជំនុំជម្រះបានត្រួតពិនិត្យថាតើការបដិសេធសំណើរួមសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម គឺមានលក្ខណៈត្រឹមត្រូវឬទេ[៤៥]។ អង្គជំនុំជម្រះយល់ឃើញថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំនេះមានសុពលភាព[៤៦]។ ក្នុងការសម្រេចនេះ អង្គជំនុំជម្រះបានកត់សម្គាល់ថា "ដោយសារភាពមិនច្បាស់លាស់របស់សំណើនេះ ការអនុញ្ញាត

[៤៤] វិធាន ២១(៤) ("ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប") សូមមើលផងដែរពី ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ បូករួមជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា ៣៣ ("អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន")។

[៤៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ D164/3/6 កថាខណ្ឌ ២៧។

[៤៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៤។

ចំពោះសំណើសុំ ប្រាកដជាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ក្នុងការពន្យារនីតិវិធីដោយមិនត្រឹមត្រូវ"[៤៧]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានសង្កេតឃើញថា ("ផ្ទុយនឹងអ្វីដែលអះអាងដោយសហមេធាវីការពារក្តី សហចៅក្រមស៊ើបអង្កេតមិនផ្អែកលើសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ ដើម្បីធ្វើជាសំអាងហេតុក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរនោះឡើយ។ ប៉ុន្តែការយោងរបស់សហចៅក្រមស៊ើបអង្កេតទៅលើសិទ្ធិជាសារវន្តនេះ គឺដើម្បីពន្យល់អំពីភាពសំខាន់របស់សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលត្រូវតែមានភាពច្បាស់លាស់ និងពាក់ព័ន្ធទៅនឹងការបង្ហាញការពិតតែប៉ុណ្ណោះ"[៤៨]។

៣០. សំណើរួមរបស់ជនជាប់ចោទ សុំតទល់ជាមួយសាក្សីទាំងអស់ដែលបានផ្តល់ចម្លើយនៅក្នុងសំណុំរឿង គឺជាបន្ទុកដ៏ធ្ងន់ធ្ងរដូចគ្នា ហើយការបដិសេធមិនពិចារណាទៅលើការថ្លឹងថ្លែងពីផលប្រយោជន៍នៃការទទួលយកភស្តុតាងដោយមិនមានការតទល់ គឺគ្មានភាពច្បាស់លាស់ និងមិនជាក់លាក់នោះឡើយ។ សំណើបែបនេះនឹងបំពានទៅលើសិទ្ធិជាសារវន្ត ក្នុងការជំនុំជម្រះដោយគ្មានការពន្យារពេលដោយមិនត្រឹមត្រូវ ព្រមទាំងបំពានទៅលើគោលដៅរបស់របស់តុលាការទាក់ទិននឹងប្រសិទ្ធភាព ដូចមានចែងក្នុងវិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

## VII បញ្ហានីតិវិធី ព្រមទាំងភស្តុតាងដែលទទួលបានតាមរយៈការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៣១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគាំទ្រចំពោះការពិភាក្សារបស់សហព្រះរាជអាជ្ញា ស្តីពីការអនុវត្តគោលការណ៍អន្តរជាតិនៅចំពោះមុខ អ.វ.ត.ក ហើយយើងយល់ស្របថា អង្គជំនុំជម្រះគួរទទួលយកគោលការណ៍ណែនាំពីគោលការណ៍អន្តរជាតិទាំងអស់នេះ ហើយរៀបចំកែសម្រួលគោលការណ៍ណែនាំទាំងអស់នេះឲ្យស្របតាមនីតិវិធីរបស់ អ.វ.ត.ក[៤៩]។ ក្នុងការរៀបចំកែសម្រួលបទដ្ឋានទាំងអស់នេះឲ្យស្របនឹង អ.វ.ត.ក អង្គជំនុំ

---

[៤៧] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤០។

[៤៨] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤៥។

[៤៩] សូមមើល សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០ ដល់៤០។

ជម្រះសាលាដំបូងគួរធ្វើការពិចារណាពីលក្ខណៈពិសេស នៃការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ហើយអង្គជំនុំជម្រះគួរទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានចាត់ទុកដូចជាសាក្សី តាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នោះឡើយ[៥០]។

៣២. តុលាការអន្តរជាតិនានាបានទទួលស្គាល់វិធានការនានា ដែលអាចប្រើប្រាស់សម្រាប់ស្វែងរកនូវភាពអាចជឿជាក់បានចំពោះឯកសារ។ ទោះបីជាវិធាន ៩២ស្ទួន នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY/ICTR បានរៀបរាប់ពីកាលៈទេសៈជាក់លាក់នានា ដូចជាការបញ្ជាក់ដែលធ្វើឡើងដោយមន្ត្រីរបស់តុលាការ ឬដំណើរការរបស់រដ្ឋ[៥១] ដែលនឹងកំណត់នូវភាពអាចជឿជាក់បានចំពោះឯកសារជាលាយលក្ខណ៍អក្សរ ក្នុងគោលដៅដើម្បីអាចឲ្យទទួលយកឯកសារនោះទៅក្នុងការជំនុំជម្រះដោយមិនចាំបាច់មានការតទល់ដោយផ្ទាល់មាត់ក៏ដោយ ក៏កាលៈទេសៈជាក់លាក់ដែលមានរៀបរាប់នៅក្នុងវិធានទាំងនេះ មានចំនួនកំណត់ប៉ុណ្ណោះ[៥២]។ ដូចគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិបានកត់សម្គាល់បន្ថែមថា "អង្គជំនុំជម្រះត្រូវតែប្រុងប្រយ័ត្ន ដោយមិនត្រូវដាក់ចេញនូវការកម្រិតកំណត់បែបសិប្បនិមិត្ត ទៅលើសមត្ថភាពរបស់ខ្លួន ក្នុងការពិចារណាទៅលើភ័ស្តុតាងនានាដោយសេរី ហើយត្រូវស្ថិតក្រោមតម្រូវការនៃភាពយុត្តិធម៌"[៥៣]។ ទោះបីជាមានការបញ្ជាក់ជាផ្លូវការសម្រាប់ជាមធ្យោបាយក្នុងការបញ្ជាក់ទៅលើភាពអាចជឿជាក់បាន ចំពោះសក្ខីកម្មជាលាយលក្ខណ៍អក្សរនេះក៏ដោយ ក៏នៅមានកត្តាដទៃទៀតដែលអាចប្រើប្រាស់បាន[សម្រាប់បញ្ជាក់ពីភាពអាចជឿជាក់បាននេះ]។

---

[៥០] សូមមើលវិធាន ២៣ [គោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី] និងវិធាន ២៤ [សាក្សី] នៃវិធានផ្ទៃក្នុង។

[៥១] សូមមើលវិធាន ៩២ស្ទួន(ខ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង របស់តុលាការ ICTY ។

[៥២] រដ្ឋអាជ្ញា តទល់នឹង Aleksovski, IT-95-14/1[ICTY] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ស្តីពីការទទួលយកភ័ស្តុតាង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៥។

[៥៣] រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo, ICC-01/04-01/06 សេចក្តីសម្រេចស្តីពីការទទួលយកឯកសារចំនួនបួន ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩។

៣៣. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការកត់សម្គាល់ថា ទាក់ទិនដល់ទម្រង់បែបបទព័ត៌មានជនរងគ្រោះ បទដ្ឋាននៃភ័ស្តុតាងព្រមទាំងដំណើរការនីតិវិធី ដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្ត ក្នុងការពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ បានរួមបញ្ចូលនូវកត្តាតម្រូវនៃភាពអាចជឿជាក់បានមួយចំនួន។ ជាឧទាហរណ៍ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែផ្តល់ភ័ស្តុតាងអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម ព្រមទាំងព្យសនកម្មដែលខ្លួនបានទទួល ហើយប្រាប់ពីទំនាក់ទំនងរវាងកត្តាទាំងពីរនេះ។ ភ័ស្តុតាងបែបនេះត្រូវតែបំពេញបានតាមបទដ្ឋាន "មានភាពពិតប្រាកដ"[៥៤]។ កត្តាតម្រូវនៃភាពអាចជឿជាក់បានមួយទៀត នៅក្នុងដំណើរការនេះ រួមមានការចុះហត្ថលេខា ព្រមទាំងចុះកាលបរិច្ឆេទ នៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី រួមទាំងការអះអាងថាព័ត៌មានទាំងអស់ដែលបានផ្តល់ក្នុងបែបបទនេះពិតជាត្រឹមត្រូវពិតប្រាកដមែន ប្រសិនបើមានចំណុចណាមិនពិត នឹងសូមទទួលទោសតាមច្បាប់ជាធរមាន[៥៥]។

៣៤. យើងសូមធ្វើការកត់សម្គាល់ថា ជនជាប់ចោទមិនបានធ្វើការជំទាស់ណាមួយនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីពឹងផ្អែកទៅលើឯកសារទាំងនេះ ក្នុងពេលដែលយើងបានប្តឹងឧទ្ធរណ៍ទាក់ទិនដល់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ២៣ស្ទួន(២)នោះទេ។ ជនជាប់ចោទក៏មិនបានជំទាស់ ឬស្នើសុំធ្វើការតទល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមទៅតាមវិធាន ៥៩(៤)ផងដែរ[៥៦]។ សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហ

---

[៥៤] វិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

[៥៥] សូមមើល ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលមាននៅក្នុងគេហទំព័រ http://vss.eccc.gov.kh/en/documentation/form

[៥៦] ចំណុចសំខាន់សម្រាប់គម្រោងការណ៍ដំណើរការនីតិវិធីរបស់ អ.វ.ត.ក គឺវិធានផ្ទៃក្នុង ដែលបានផ្តល់នូវឱកាសយ៉ាងច្រើនដល់ជនជាប់ចោទ ដើម្បីធ្វើការតទល់ជាមួយសាក្សី ហើយនឹងដើម្បីជំទាស់ទៅលើ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ នៅក្នុងដំណាក់កាលមុនការជំនុំជម្រះ។ ទោះបីជាមានឱកាសច្រើនបែបនេះក៏ដោយ ក៏ជនជាប់ចោទមិនបានលើកឡើងនូវសំណើសុំតទល់ ឬការជំទាស់ណាមួយឡើយ។ ដោយសារតែវាជាចេតនារបស់ជនជាប់ចោទ ក្នុងការទាមទារសិទ្ធិដាច់ខាតក្នុងការតទល់នៅក្នុងដំណាក់កាលជំនុំជម្រះបែបនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមជំទាស់ថា វាជាកលល្បិចរបស់មេធាវីការពារ

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថា បទដ្ឋាននៃភស្តុតាងដែលប្រើប្រាស់សម្រាប់ដីកាសម្រេចស្តីពីការទទួលយក[ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង] គឺមានលក្ខណៈខុសគ្នាពីបទដ្ឋាននៃភស្តុតាងដែលត្រូវប្រើប្រាស់នៅក្នុងការជំនុំជម្រះ។ ក៏ប៉ុន្តែសម្រាប់សំណួរដែលសួរថា តើឯកសារទាំងនោះមានបុរេវិនិច្ឆ័យចំពោះជនជាប់ចោទឬអត់នោះ ការដែលជនជាប់ចោទមិនបានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារទាំងនោះក្នុងពេលជំនុំជម្រះកន្លងមក បានបង្ហាញថាខ្លឹមសាររបស់ឯកសារទាំងនោះ សឹងតែគ្មានផលប៉ះពាល់បុរេវិនិច្ឆ័យ[៥៧]។

៣៥. ដោយសារតែមានវិធានការបញ្ជាក់ពីភាពអាចជឿជាក់បាន ហើយដោយសារតែភស្តុតាងទាំងនោះមិនបានបង្ហាញដោយផ្ទាល់ពីការប្រព្រឹត្តរបស់ជនជាប់ចោទ ឬដោយសារតែភស្តុតាងទាំងនោះមានលក្ខណៈផ្ទុំគ្នា ទើបតុលាការអាចយល់ឃើញថា ខ្លួនអាចទទួលយកភស្តុតាងដោយមិនចាំបាច់មានការតទល់ដោយផ្ទាល់មាត់នោះទេ។

៣៦. ដោយពិចារណាទៅលើអង្គហេតុដែលថា ក្នុងការរៀបចំបង្កើត អ.វ.ត.ក គេបានប្រមើលមើលពីដំណើរការនីតិវិធី ដែលភាគច្រើនត្រូវធ្វើឡើងតាមរយៈសារណាជាលាយលក្ខណ៍អក្សរ ដោយរួមបញ្ចូលទាំងដំណាក់កាលស៊ើបអង្កេតដ៏វែងអន្លាយនោះ ដូច្នេះវាជាកត្តាចាំបាច់មិនអាចបដិសេធបានសម្រាប់ប្រសិទ្ធភាព និងរដ្ឋបាលតុលាការដ៏ល្អ ក្នុងការធានាថា ឯកសារជាលាយលក្ខណ៍អក្សរមិនចាំបាច់ត្រូវធ្វើឡើងជាន់គ្នា ដោយសារតែសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សីនោះទេ។ សិទ្ធិដាច់ខាតនេះនឹងនាំទៅដល់ការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ដែលមានលក្ខណៈដដែលៗ ហើយចំណាយពេលវេលាច្រើន ចំពោះបញ្ហាដែលអាចកំណត់បានដោយគ្រប់គ្រាន់តាមរយៈកំណត់ត្រាជាលាយលក្ខណ៍អក្សរតែមួយ។

---

ក្តី នៅពេលដែលសវនាការដ៏សំខាន់ជិតនឹងចាប់ផ្តើមទៅហើយ ទើបពួកគេទាមទារថាខ្លួនមិនមានឱកាសក្នុងការសួរដេញដោលសាក្សី ឬក៏ពិនិត្យមើលលើភស្តុតាងដែលសាក្សី អាចនឹងដាក់ជូនអង្គជំនុំជម្រះ។

[៥៧] បន្ថែមពីលើនេះទៀត ជនជាប់ចោទក៏បានទទួលឱកាសក្នុងការជំទាស់ទៅនិង ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ក្នុងពេលដែលមានបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពី ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមវិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុង។ ក៏ប៉ុន្តែក្នុងពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ មិនមានការជំទាស់ណាមួយឡើយ។

00722142



## VIII **សេចក្តីសន្និដ្ឋាន**

៣៧. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យ

i. អង្គជំនុំជម្រះសាលាដំបូងមេត្តាប្រកាសថាជនជាប់ចោទមិនមានសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយសាក្សីទាំងអស់ ដែលចម្លើយរបស់ពួកគាត់ត្រូវបានដាក់ជាភស្តុតាងនោះឡើយ ហើយ

ii. អនុម័តយកបទដ្ឋានអន្តរជាតិសម្រាប់ការទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដោយគិតពិចារណាដល់យន្តការនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក។

សូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះដោយគោរពពី

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ | **ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |
| | Nushin SARKARATI<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | **សំ សុគង់**<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |